**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជារំលឹកវិញ្ញាណក្ខន្ធជនរងគ្រោះ និងការឈឺចាប់ពីឧក្រិដ្ឋកម្ម ក្នុងរបបប៉ុលពត**
**ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នៅតាំងគោក**
**ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៨**
***យើងរួបរួមគ្នានៅក្នុងសេរីភាពនៃជំនឿ***

អត្ថបទទី១៖ កក ២០,២៨-៣៨
ដំណឹងល្អ៖ យហ ១២,២៣-២៦

លោកកាឌីណាល់ ជាទីគោរព

លោកអភិបាល ជាស្រឡាញ់

លោកបូជាចារ្យ ជាទីស្នេហា

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះជាថ្ងៃដែលពិសេសបំផុត សម្រាប់ព្រះសហគមន៍របស់យើងនៅក្នុងប្រទេសកម្ពុជាទាំងមូល។ លោកអភិបាលទាំងបី និងលោកកាឌីណាល់ យើងមានអាវប្លែកខ្ញុំរើសសម្រាប់ថ្ងៃនេះ គឺលោកអន់តូនី អាវនោះជាអាវដែលខ្ញុំបានទទួលនៅថ្ងៃតែងតាំងមរណសាក្សីនៅប្រទេសកូរ៉េ លោកតីគេ គាត់មានអាវដែលខ្ញុំបានទទួលនៅថ្ងៃតែងតាំងមរណសាក្សីនៅប្រទេសឡាវ ខ្ញុំមានអាវដែលខ្ញុំបានទទួលនៅពេលខ្ញុំបានជួបសម្តេចប៉ាបនៅប្រទេសមីយ៉ាន់ម៉ា និងលោកកាឌីណាល់ គាត់មានអាវដែលយើងមានសម្រាប់ប្រទេសកម្ពុជាយើង។ ដូច្នេះ តាមរយៈអាវនីមួយៗបីដូចជាយើងមានព្រះសហគមន៍កូរ៉េ ព្រះសហគមន៍ឡាវ ព្រះសហគមន៍មីយ៉ាន់ម៉ា ព្រះសហគមន៍ភូមា និងមរណសាក្សីយ៉ាងច្រើន យើងមានមរណសាក្សីនៅកូរ៉េជាង១០០នាក់ មរណសាក្សីនៅប្រទេសឡាវ១៧នាក់ និងព្រះសហគមន៍របស់យើងដែលជួបជុំគ្នាដើម្បីអធិដ្ឋានកោតសរសើរព្រះជាម្ចាស់។

ថ្ងៃនេះយើងអាចនិយាយថា អារម្មណ៍របស់យើងសប្បាយផង រំភើបផង ព្រួយចិត្តផង ចង់កោតសរសើរព្រះជាម្ចាស់ផង។ យើងពោរពេញដោយអំណរសប្បាយ ដោយសារថ្ងៃនេះយើងទទួលស្វាគមន៍លោកកាឌីណាល់។ ដោយស្វាគមន៍លោកកាឌីណាល់ លើទឹកដីតាំងគោកបីដូចជាយើងស្វាគមន៍សម្តេចប៉ាប ដោយសារកាឌីណាល់ជាក្រុមទីព្រឹក្សាផ្ទាល់របស់សម្តេចប៉ាប មានតែ១២០អង្គទូទាំងពិភពលោក។ ដូច្នេះថ្ងៃនេះលោក កាឌីណាល់មកសួរសុខទុក្ខយើងខ្ញុំ បីដូចជាសម្តេចប៉ាបមកសួរសុខទុក្ខយើងខ្ញុំដែរ។ ជាពិសេស សប្តាហ៍មុនលោកកាឌីណាល់បានទៅទីក្រុងរ៉ូមនឹងបាននិយាយជាមួយសម្តេចប៉ាបជិតមួយម៉ោងផ្ទាល់ខ្លួន ដូច្នេះថ្ងៃនេះបីដូចជាសម្តេចប៉ាបប្រាំងស៊ីស្កូ នៅជាមួយយើងខ្ញុំតាមរយៈលោកកាឌីណាល់។ ម្យ៉ាងទៀត តាមរយៈលោកកាឌី

ណាល់យើងទទួលស្វាគមន៍ព្រះសហគមន៍ឡាវ ដែលមកជួបព្រះសហគមន៍កម្ពុជា។ តាមរយៈលោកកាឌីណាល់ ជាមរណសាក្សីនៅប្រទេសឡាវដែលមកជួបជាមួយបងប្អូនទាំងអស់ ដែលបានទទួលមរណភាពនៅក្នុងសម័យប៉ុលពត និងជាពិសេសដល់មរណសាក្សីរបស់យើង។

ថ្ងៃនេះយើងបានសរសេរជាផ្លូវការថា **ពិធីរំលឹកវិញ្ញាណក្ខន្ធជនរងគ្រោះ និងការឈឺចាប់ពីឧក្រិដ្ឋកម្មក្នុងរបបប៉ុលពិត ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។** រាជរដ្ឋាភិបាលកម្ពុជា ដាក់ឲ្យយើងគោរពពីឆ្នាំនេះតទៅ រាល់ថ្ងៃទី២០ ខែឧសភា យើងមានបុណ្យចងចាំ ដើម្បីនឹករលឹកដល់បងប្អូនទាំងអស់ដែលបានទទួលមរណភាពនៅក្នុងសម័យប៉ុលពត។ ដូច្នេះថ្ងៃនេះ យើងភ្ជាប់នឹងពិធីបុណ្យនេះ ដើម្បីនឹករលឹកដល់មរណសាក្សីផង និងនឹករលឹកដល់បងប្អូនខ្មែរដែលបានស្លាប់ក្នុងសម័យនោះផង។ យើងអរព្រះគុណព្រះជាម្ចាស់ និងកោតសរសើរព្រះជាម្ចាស់សម្រាប់ជីវិតដែលមរណសាក្សីនៅប្រទេសឡាវបានប្រទាន ដោយការស៊ើបអង្កេត ការយកចិត្តទុកដាក់ ជាពិសេសលោកកាឌីណាល់បានជួយយ៉ាងច្រើន យកចិត្តទុកដាក់ទាំងការអធិដ្ឋាន ទាំងសេចក្តីក្លាហាន ដើម្បីឈ្នះគ្រប់ឧបសគ្គ។ ឆ្នាំ២០១៦ ព្រះសហគមន៍ទទួលស្គាល់ លោក យ៉ូសែប ទៀន និងសហការី១៦នាក់ ជាមរណសាក្សីនៅប្រទេសឡាវ។ ថ្ងៃនេះខ្ញុំជឿថាមរណសាក្សីនៅប្រទេសឡាវកំពុងសម្លឹងមើលពីស្ថានបរមសុខ ដើម្បីផ្តល់កម្លាំងឲ្យយើងនៅក្នុងជំនឿរបស់យើង ជាគ្រីស្តបរិស័ទនៅប្រទេសកម្ពុជា។ ខ្ញុំជឿថា មរណសាក្សីនៅប្រទេសឡាវនៅស្ថានបរមសុខ កំពុងចាប់ដៃបងប្អូនមរណសាក្សីនៅប្រទេសកម្ពុជាយើង ដែលមិនទាន់មានឈ្មោះជាផ្លូវការ ដើម្បីអធិដ្ឋានសម្រាប់យើងទាំងអស់គ្នានៅទីនេះ។

ពិតមែន ព្រះសហគមន៍ចូលរួមដើម្បីនឹករលឹក ដល់វិញ្ញាណក្ខន្ធរបស់បងប្អូនទាំងអស់ដែលបានទទួលមរណភាពនៅក្នុងសម័យប៉ុលពត ជាពិសេសដល់មរណសាក្សីរបស់យើងដែលជាតំណាងនៃគ្រីស្តបរិស័ទដែលសុខចិត្តលះបង់ចោលជីវិត បូជាជីវិត ដើម្បីឲ្យយើងមានជីវិត។ ស្រែដែលយើងមាននៅជុំវិញឈើឆ្កាង ទៅជាសញ្ញានៃជីវិត ផ្កាក្រហម ជាសញ្ញានៃឈាមរបស់មរណសាក្សី ផ្កាស ជាសញ្ញានៃភាពដ៏វិសុទ្ធ ទាំងអស់ជាសញ្ញាសម្គាល់នៃជីវិតដ៏បរិបូរណ៍ដែលយើងបានទទួលតាមរយៈមរណសាក្សី ពីព្រះយេស៊ូគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ។ ថ្ងៃនេះយើងពោរពេញដោយអំណរសប្បាយ យើងអរព្រះគុណព្រះជាម្ចាស់សម្រាប់មរណសាក្សីដែលបានសាបព្រោះជីវិតថ្មី ដល់ព្រះសហគមន៍ឡាវនិងកម្ពុជា។ ថ្ងៃនេះយើងរំភើបដែរ យើងព្រួយចិត្តដែរ ដោយនឹករលឹកដល់បងប្អូនខ្មែរយើងរាប់លាននាក់ ដែលបានទទួលមរណភាពនៅក្នុងសម័យប៉ុលពត ណែនាំឲ្យយើងនឹកឃើញដល់អំពើបាប ដែលចូលនៅក្នុងដួងចិត្តរបស់មនុស្ស និងណែនាំឲ្យយើងបាត់បង់សេចក្តីសង្ឃឹម។ អំពើបាបដែលបំផ្លាញ អំពើបាបដែលមើលងាយ

អំពើបានដែលសម្លាប់ អំពើបាបដែលណែនាំឲ្យអ្វីទាំងអស់រលាយសាបសូន្យ យើងនឹកឃើញដល់បងប្អូនរាល់លាននាក់ដែលបានស្លាប់នៅក្នុងសម័យប៉ុលពត ដល់បងប្អូនរាប់មឺននាក់ដែលសព្វថ្ងៃកំពុងស្លាប់ដោយគ្មានមូលហេតុ ឥតកំហុសសោះ ដោយសារសង្គ្រាម។ យើងនឹកឃើញដល់ពេលវេលា ដែលលោកកាឌីណាល់បានជាប់នៅក្នុងមន្ទីរឃុំឃាំងបីឆ្នាំ ដោយគ្មានមូលហេតុ។ នៅពេលលោកកាឌីណាល់ សួរគេថាមូលហេតុអ្វីចាប់ខ្ញុំ គេឆ្លើយថា លោកបានផ្សព្វផ្សាយសាសនាយេស៊ូ លោកកាឌីណាល់ថា ខ្ញុំមិនដែលផ្សព្វផ្សាយសាសនាទេ គេតបទៀតថា វត្តមានរបស់លោកបីដូចជាវត្តមានរបស់ព្រះយេស៊ូ។ យើងនឹកឃើញដល់ព្រះយេស៊ូដែលសោយទិវង្គត់លើឈើឆ្កាង ព្រះយេស៊ូជាព្រះដ៏សុចរិត ជាព្រះដ៏វិសុទ្ធ ដែលឥតមានមូលហេតុត្រូវស្លាប់លើឈើឆ្កាង នេះដោយសារព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់។

បងប្អូនជាទីស្រឡាញ់!

ព្រឹកនេះជាឱកាសមួយដើម្បីអធិដ្ឋាន សម្រាប់បងប្អូនទាំងអស់ដែលបានស្លាប់ ដែលបន្តស្លាប់ នៅក្នុងពិភពលោករបស់យើងដោយគ្មានមូលហេតុ។ ជាឱកាសមួយដើម្បីសម្លឹងមើលអាថ៌កំបាំងនៃជំនឿរបស់យើង ការអស្ចារ្យនៃជំនឿរបស់យើង ជាពិសេសនៅក្នុងរដូវបុណ្យសម្លងនេះ ដែលយើងមិនគោរពព្រះឈើឆ្កាងនៃការសោយទិវង្គត់របស់ព្រះយេស៊ូទេ គឺយើងគោរពព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ។ ពីសេចក្ដីស្លាប់ ព្រះយេស៊ូបានណែនាំឲ្យយើងចូលនៅក្នុងជីវិត ពីភាពងងឹតព្រះយេស៊ូបានណែនាំឲ្យយើងចូលនៅក្នុងពន្លឺ នេះជាផ្លូវនៃជីវិត និងជំនឿរបស់យើងជាគ្រីស្តបរិស័ទ រួមជាមួយព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ យើងដឹងថាចាប់ពីពេលនេះតទៅសេចក្ដីស្លាប់លែងឈ្នះអ្វីៗទាំងអស់ តែជាជីវិតដែលឈ្នះគ្រប់ពេលវេលា។ នេះជាផ្លូវដែលមរណសាក្សីរបស់យើង បានសម្រេចចិត្តទទួលនៅប្រទេសឡាវ នៅប្រទេសកម្ពុជាបានសម្រេចចិត្តនៅរហូតដល់ទីបញ្ចប់ ដោយសារនៅពេលនោះគេមានសិទ្ធិជ្រើសរើសទៅប្រទេសមួយទៀត ប៉ុន្តែគេបានសម្រេចចិត្តនៅ ដើម្បីនៅជាមួយបងប្អូនគ្រីស្តបរិស័ទនិងជាមួយប្រជាជនផ្ទាល់ខ្លួន។ នៅព្រឹកនេះ ឲ្យយើងបើកត្រចៀករបស់យើង ដើម្បីស្ដាប់សម្លេងរបស់លោកឪពុកឆ្នារ សាឡឹម នៅថ្ងៃបុណ្យចម្លងមុនខ្មែរក្រហមចូលនៅក្នុងទីក្រុងភ្នំពេញ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៥ គ្រីស្តបរិស័ទនៅពោធិ៍ចំបានផ្ដល់សក្ខីភាពប៉ុន្មានថ្ងៃមុនថា នៅថ្ងៃនោះលោកឪពុកឆ្នារ សាឡឹម បានមកថ្វាយអភិបូជាបុណ្យចម្លងជាមួយយើង និងណែនាំឲ្យយើងសប្បាយដោយសារព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ដោយដឹងថាទីក្រុងភ្នំពេញចូលនៅក្នុងភាពងងឹតអស់ហើយ មានគ្រាប់បែកនៅគ្រប់កន្លែងជុំវិញទីក្រុងភ្នំពេញ ដោយសារដឹងថាសេចក្ដីសង្ឃឹម

របស់យើងដែលអាចរស់នៅលើលោកីយនេះតិចមែនទែន ប៉ុន្តែយើងពោរពេញដោយសេចក្តីសង្ឃឹមដោយសារជីវិតដែលយើងទទួលពីព្រះយេស៊ូ។

លោកអភិបាល ឆ្មារ សាឡាស់ បានសរសេរនៅប្រទេសបារាំង ក្នុងខែមករា ឆ្នាំ១៩៧៥ មុនធ្វើដំណើរត្រលប់មកប្រទេសកម្ពុជាវិញ បានសរសេរថា "**ខ្ញុំផ្ញើអនាគតរបស់ខ្ញុំ សូមណែនាំឲ្យអនាគតរបស់ខ្ញុំដើរលើផ្លូវនៃជីវិតអស់កល្បជានិច្ច**"។ នៅតាំងគោក ឲ្យយើងមើលលោកអភិបាល ឆ្មារ សាឡាស់ មើលលោកឪពុក ឆ្មារ សាឡឹម មើលលោកឪពុក ចម្រើន ដែលបានដើរតាមភូមិនីមួយៗ ទៅតាមផ្ទះនីមួយៗយ៉ាងស្វាត់ដើម្បីសួរសុខទុក្ខគ្រីស្តបរិស័ទ ដើម្បីអធិដ្ឋានសម្រាប់អ្នកជំងឺ។ មើលលោកអភិបាល ឆ្មារ សាឡាស់ មើលលោកឪពុក ឆ្មារ សាឡឹម មើលលោកឪពុក ចម្រើន ដែលអធិដ្ឋាន ដែលថ្វាយអភិបូជា លើគ្រែដែលយើងមាននៅតាំងគោកនេះ ដើម្បីធ្វើជីវិតទៅលើព្រះជាម្ចាស់។ នៅពេលនេះឲ្យយើងស្តាប់សម្លេងរបស់បងស្រី លីលី នៅផ្សារបារាយណ៍ បងស្រីបានច្រៀងជាភាសាឡាតាំង ពាក្យកោតសរសើរព្រះជាម្ចាស់ នៅពេលគាត់កំពុងថែរក្សាកូនក្មេងដែលឪពុកម្តាយបានទុកពេលពួកគាត់ទៅធ្វើស្រែ ទៅធ្វើការងារយ៉ាងធ្ងន់ និងមានឪពុកម្តាយមួយចំនួនមិនបានត្រលប់មកវិញទេ ដោយសារអង្គការនាំទៅរៀនសូត្រ(យកទៅសម្លាប់)។ នៅពេលនេះឲ្យយើងមើលឃើញ លោកកាឌីណាល់ផ្ទាល់ ដែលបាននៅក្នុងមន្ទីរឃុំឃាំង ជាមួយលោកអភិបាល ទីតូ ពេលបុណ្យព្រះយេស៊ូប្រសូត លោកទាំងពីរបានចាប់កណ្តុរដែលរត់នៅក្នុងគុក ដើម្បីយកមកជប់លៀងអបអរសាទរបុណ្យព្រះយេស៊ូប្រសូត ដោយសារពួកគាត់បានថែរក្សាសេចក្តីសង្ឃឹមនៅក្នុងជំនឿរបស់ពួកគាត់។ ជាពិសេស ពាក្យដែលលោកកាឌីណាល់បាននិយាយថា "**បីឆ្នាំដែលជាប់ក្នុងមន្ទីរឃុំឃាំង បីឆ្នាំដែលមិនបានថ្វាយអភិបូជា ប៉ុន្តែខ្ញុំផ្ទាល់ខ្លួនខ្ញុំបានធ្វើសក្ការបូជាសម្រាប់ព្រះជាម្ចាស់ ជីវិតរបស់ខ្ញុំទៅជាយញ្ញបូជា ដើម្បីភ្ជាប់ជាមួយព្រះយេស៊ូដែលជាយញ្ញបូជាដ៏ខ្ពង់ខ្ពស់បំផុត**"។ ពេលយើងស្តាប់នេះ យើងឃើញសេចក្តីសង្ឃឹមដែលយើងមាន ដោយសារសេចក្តីស្លាប់ មិនមែនបញ្ចប់នៃជីវិត លោកកាឌីណាល់ជាសាក្សីរស់ បានផ្តល់សក្ខីភាពនៃសេចក្តីសង្ឃឹម។ ខ្ញុំអញ្ជើញបងប្អូនទាំងអស់ ឲ្យយើងទៅជាប្រជារាស្ត្រនៃសេចក្តីសង្ឃឹម ដូចសក្ខីភាពទាំងអស់ខាងលើទៅជាកម្លាំងសម្រាប់ព្រះសហគមន៍របស់យើង ដោយនឹកឃើញពិតមែន ជំនឿអាចណែនាំឲ្យយើងទទួលកម្លាំងពិសេស។ នៅពេលយើងជួបទុក្ខលំបាក នៅពេលយើងជួបទុក្ខវេទនា នៅពេលនោះជំនឿទៅជាកម្លាំងណែនាំឲ្យយើងទទួលជីវិតនិងកម្លាំងមួយយ៉ាងពិសេស។ យើងពោរពេញដោយសេចក្តីសង្ឃឹម ដើម្បីឲ្យយើងរួមគ្នាអាចបង្កើតពិភពថ្មីសម្រាប់កូនចៅរបស់យើង។ យើងដឹងថានៅក្នុងដៃរបស់យើង ថ្ងៃនេះយើងអំណាចមួយយ៉ាងពិសេសដើម្បីបង្កើតពិភពលោកថ្មី។ ព្រះនាងម៉ារី ដែលជាមាតារបស់ព្រះជាម្ចាស់ ព្រះនាង

ម៉ារីដែលជាមាតារបស់ព្រះសហគមន៍ ព្រះនាងម៉ារីគ្រប់ពេលវេលាបានពោរពេញដោយអំណរសប្បាយ នៅក្នុងការបម្រើ ដែលបានតស៊ូជានិច្ចដើម្បីរៀបចំខ្លួនទៅដល់ស្ថានបរមសុខ។ ថ្ងៃនេះរួមជាមួយព្រះនាងម៉ារី ឲ្យយើងពោរពេញដោយអំណរសប្បាយ ឲ្យយើងទៅជាអ្នកបម្រើជានិច្ចដោយតស៊ូដើម្បីរកឃើញទ្វារដែលណែនាំឲ្យយើងទៅស្ថានបរមសុខ។

ថ្ងៃនេះយើងអធិដ្ឋាន សម្រាប់ព្រះសហគមន៍របស់យើងទាំងនៅប្រទេសឡាវ ទាំងនៅប្រទេសកម្ពុជា ដើម្បីឲ្យយើងរួបរួមគ្នានៅក្នុងសេរីភាពនៃជំនឿ សេរីភាពនៃជីវិត សេរីភាពនៃការចែករំលែកសេចក្តីស្រឡាញ់ដល់បងប្អូនឯទៀតៗ ជាពិសេសធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ ជាពិសេសយើងអធិដ្ឋាន ដើម្បីឲ្យព្រះសហគមន៍របស់យើងទាំងពីរ ឡាវ-កម្ពុជា អាចជួបជុំគ្នាយ៉ាងញឹកញាប់តាមរយៈគ្រីស្តបរិស័ទ តាមរយៈនិស្សិតទេវវិទ្យាល័យ តាមរយៈលោកអភិបាល និងបូជាចារ្យ ជាឱកាសមួយដើម្បីទទួលកម្លាំងឲ្យគ្នាទៅវិញទៅមក។ សូមលោកកាឌីណាល់ ផ្ញើសួរសុខទុក្ខពីព្រះសហគមន៍នៅប្រទេសកម្ពុជាដល់សម្តេចប៉ាប យើងទាំងអស់គ្នាអធិដ្ឋានសម្រាប់សម្តេចប៉ាបជានិច្ច។ យើងអធិដ្ឋានសម្រាប់លោកកាឌីណាល់ សម្រាប់ព្រះសហគមន៍នៅប្រទេសឡាវ ព្រះសហគមន៍យើងទាំងពីរយើងមានចិត្តតែមួយ ជំនឿតែមួយ សេចក្តីសង្ឃឹមតែមួយ មិត្តភាពតែមួយ។

ជ័យោព្រះសហគមន៍កម្ពុជា-ឡាវ! អាម៉ែន៕